00652427

E9/5/1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 03 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-9-2007/ECCC/TC

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀងធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

ផាត់ ពៅសៀង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

១. ក្រោយពីបានផ្តល់ឱកាសដល់គ្រប់ភាគី ដើម្បីលើកនូវបញ្ហាដែលខ្លួនមានបំណងយកមកពិភាក្សា អង្គជំនុំជម្រះសូមផ្តល់នូវរបៀបវារៈដូចខាងក្រោមសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ដែលគ្រោងនឹងប្រព្រឹត្តិទៅពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១១ (E9/5)។ កាលបរិច្ឆេទនេះគ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អនុលោមតាមវិធាន ៧៩(៧) នៃវិធានផ្ទៃក្នុង កិច្ចប្រជុំនេះនឹងត្រូវធ្វើឡើងដោយសម្ងាត់។

២. ដោយសារតែរបៀបវារៈនីមួយៗនៃកិច្ចប្រជុំនេះមានលក្ខណៈនីតិវិធី និងបច្ចេកទេស ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីមិនតម្រូវឱ្យចូលរួមក្នុងកិច្ចប្រជុំនេះទេ ។ សហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទនីមួយៗត្រូវបានអនុញ្ញាតឱ្យអមមកជាមួយនូវបុគ្គលិកផ្នែកច្បាប់ចំនួនបួន (០៤) នាក់ លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះដោយអង្គជំនុំជម្រះ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យអមមកជាមួយនូវមេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួន(០៤)នាក់ ប៉ុន្តែ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗមាននូវតួនាទីជាក់លាក់ដើម្បីជួយដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលកិច្ចប្រជុំរៀបចំសវនាការ ដូចមានចែងក្នុងវិធាន ១២ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ។ ផ្នែក ឬអង្គភាពមួយចំនួនរបស់ អ.វ.ត.ក តម្រូវឱ្យត្រៀមខ្លួនដើម្បីផ្តល់នូវព័ត៌មានចាំបាច់លើរបៀបវារៈណាមួយដែលពាក់ព័ន្ធ។

**របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១១**

<u>**ថ្ងៃ អង្គារ ទី ០៥ ខែ មេសា ឆ្នាំ ២០១១**</u> (ម៉ោង ៩:០០ ព្រឹក - ម៉ោង ១៦:០០ រសៀល នៅសាលសវនាការ)

១. ការប្រកាសអំពីកាលបរិច្ឆេទសវនាការដែលអង្គជំនុំជម្រះគ្រោងនឹងធ្វើនៅពេលខាងមុខ អនុលោមតាមវិធាន ៦៨(៣) និងវិធាន ៨៩។

២. ការទទួលស្គាល់មេធាវីអន្តរជាតិ និងបញ្ហាបឋមនានា។

៣. ចំណាត់ការលើសំណើសុំរបស់ភាគី (សេចក្តីសម្រេចដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ)។

៤. ការធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃការឆ្លើយតបរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំឱ្យមានការបញ្ជាក់អំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមកិច្ចដំណើរការសវនាការ។

៥. វិធីសាស្ត្រដែលប្រមើលមើលទុកជាមុនចំពោះការកំណត់កាលបរិច្ឆេទសវនាការ។

<u>**ថ្ងៃ ពុធ ទី ០៦ ខែ មេសា ឆ្នាំ ២០១១**</u> (ម៉ោង ៩:០០ ព្រឹក - ម៉ោង ១៦:០០ រសៀល នៅសាលសវនាការ)

៦. ការបញ្ជាក់មួយចំនួនទាក់ទងទៅនឹងការរៀបចំ និងដំណើរការប្រព្រឹត្តទៅក្នុងពេលសវនាការ។

៧. ការកាត់បន្ថយចំនួនសាក្សី។

៨. បច្ចុប្បន្នភាពពីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី អំពីវឌ្ឍនភាពនៃអង្គហេតុដែលបានព្រមព្រៀង។

៩. ព័ត៌មានទូទៅចំពោះភាគីទាក់ទងនឹងលក្ខណៈគំរូនៃការពិនិត្យលើភស្តុតាង។

១០. ការជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅដំណាក់កាលសវនាការ។

**ថ្ងៃ ព្រហស្បតិ៍ ទី ០៧ ខែ មេសា ឆ្នាំ ២០១១** (ម៉ោង ៩:00 ព្រឹក - ម៉ោង ១៦:00 រសៀល នៅសាលសវនាការ)

១១. ការឆ្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តីស្នើសុំការណែនាំអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១២. ការធ្វើបច្ចុប្បន្នភាពរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីវឌ្ឍនភាពទាក់ទងនឹងការបញ្ជាក់អំពីខ្លឹមសារនៃសំណង (វិធាន ៨០ស្ទួន(៤))។

១៣. បញ្ហាផ្សេងៗ។

១៤. ការកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំរៀបចំសវនាការលើកក្រោយ និង/ឬ សវនាការបឋម។

ភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

**និល ណុន**